ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## សមាសភាព ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០២០ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៣៩ និងមាត្រា១៤៤ នៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១០ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៨៧ ចំណងជើងចំណុច "គ" ផ្នែកទី៣ នៃជំពូកទី៤ មាត្រា៨៩ មាត្រា៩០ មាត្រា៩១ មាត្រា៩៤ មាត្រា១១០ មាត្រា១២០ និងមាត្រា១២២ នៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៨/០១៥ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ កំណត់អំពីសមាសភាព ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា សរសេរអក្សរកាត់ថា "**ក.ជ.ប.អ.**" និងជាភាសាអង់គ្លេស National Council for Minimum Wage សរសេរជាអក្សរកាត់ "N.C.M.W."។

## ជំពូកទី២
## សមាសភាពរបស់ ក.ជ.ប.អ.

**មាត្រា២ .-**

**ក.ជ.ប.អ.** ត្រូវមានសមាជិកពេញសិទ្ធិយ៉ាងតិចចំនួន៤៨(សែសិបប្រាំបី)រូប ក្នុងនោះ មានប្រធាន ១(មួយ)រូប ជារដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឬតំណាង និងអនុប្រធាន ចំនួន២(ពីរ)រូប ដែលអនុប្រធាន១(មួយ)រូប ត្រូវជ្រើសរើសចេញពីសមាសភាពតំណាងអង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត និង១(មួយ)រូបទៀត ជ្រើសរើសចេញពីសមាសភាពតំណាងអង្គការវិជ្ជាជីវៈរបស់និយោជក តាមរយៈការបោះឆ្នោតផ្ទៃក្នុងរបស់ភាគីនីមួយៗ។

ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាមានសមាសភាពដូចតទៅ៖

| | | |
|---|---|---|
| - រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឬតំណាង | ១(មួយ)រូប | ប្រធាន |
| - តំណាងអង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត | ១(មួយ)រូប | អនុប្រធាន |
| - តំណាងអង្គការវិជ្ជាជីវៈរបស់និយោជក | ១(មួយ)រូប | អនុប្រធាន |
| - តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១(មួយ)រូប | សមាជិក |
| - តំណាងក្រសួងមហាផ្ទៃ | ១(មួយ)រូប | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១(មួយ)រូប | សមាជិក |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១(មួយ)រូប | សមាជិក |
| - តំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម | ១(មួយ)រូប | សមាជិក |
| - តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១(មួយ)រូប | សមាជិក |
| - តំណាងក្រសួងសាធារណការនិងដឹកជញ្ជូន | ១(មួយ)រូប | សមាជិក |
| - តំណាងក្រសួងទេសចរណ៍ | ១(មួយ)រូប | សមាជិក |
| - តំណាងក្រសួងពាណិជ្ជកម្ម | ១(មួយ)រូប | សមាជិក |
| - តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១(មួយ)រូប | សមាជិក |
| - តំណាងក្រសួងផែនការ | ១(មួយ)រូប | សមាជិក |
| - តំណាងក្រសួងរ៉ែ និងថាមពល | ១(មួយ)រូប | សមាជិក |

| | | |
|---|---|---|
| - តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១(មួយ)រូប | សមាជិក |
| - តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ១(មួយ)រូប | សមាជិក |
| - តំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | ១(មួយ)រូប | សមាជិក |
| - តំណាងគណៈកម្មាធិការផលិតភាពកម្ពុជា | ១(មួយ)រូប | សមាជិក |
| - តំណាងអង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត | ១៦(ដប់ប្រាំមួយ)រូប | សមាជិក |
| - តំណាងអង្គការវិជ្ជាជីវៈរបស់និយោជក | ១៦(ដប់ប្រាំមួយ)រូប | សមាជិក |

តំណាងភាគីនីមួយៗត្រូវមានសមាជិកបម្រុង ដែលមានចំនួនស្មើនឹងចំនួនសមាជិកពេញសិទ្ធិ ដើម្បីបំពេញជំនួសសមាជិកពេញសិទ្ធិ នៃភាគីណាមួយដែលអវត្តមាន។ សមាជិកបម្រុងដែលជំនួសសមាជិកពេញសិទ្ធិដែលអវត្តមាន មានសិទ្ធិដូចសមាជិកពេញសិទ្ធិ។

សមាជិកពេញសិទ្ធិនិងសមាជិកបម្រុងរបស់ **ក.ជ.ប.អ.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ដើម្បីជានាប្រសិទ្ធភាពការងាររបស់ **ក.ជ.ប.អ.** ឬដោយយោងលើមូលហេតុសមស្រប រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អាចស្នើឱ្យក្រសួង ស្ថាប័ន និងអង្គការវិជ្ជាជីវៈពាក់ព័ន្ធ ធ្វើការផ្លាស់ប្តូរតំណាងរបស់ខ្លួន។

**មាត្រា៣ .-**

សមាជិកពេញសិទ្ធិនិងបម្រុងរបស់ **ក.ជ.ប.អ.** ដែលមកពីខាងភាគីរាជរដ្ឋាភិបាលត្រូវមានមុខតំណែងចាប់ពីប្រធាននាយកដ្ឋានឬមានឋានៈស្មើប្រធាននាយកដ្ឋានឡើងទៅ។

សមាជិកពេញសិទ្ធិនិងបម្រុងរបស់ **ក.ជ.ប.អ.** ដែលមកពីខាងភាគីនិយោជកនិងខាងភាគីកម្មករនិយោជិត ត្រូវតែជាសមាសភាពមកពីអង្គការវិជ្ជាជីវៈរបស់និយោជកនិងអង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិតដែលមានបញ្ជិកាត្រឹមត្រូវនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៤ .-**

**ក.ជ.ប.អ.** អាចបង្កើតក្រុមការងារបច្ចេកទេសឬគណៈកម្មការជំនាញ ដើម្បីជាជំនួយក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន។ សមាសភាព តួនាទី និងភារកិច្ចរបស់ក្រុមការងារបច្ចេកទេសឬគណៈកម្មការជំនាញត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **ក.ជ.ប.អ.**។

## ជំពូកទី៣
## តួនាទីនិងភារកិច្ចរបស់ ក.ជ.ប.អ.

**មាត្រា៥ .-**

ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រនូវរាល់កិច្ចការទាំងឡាយដែលទាក់ទងនឹងប្រាក់ឈ្នួលអប្បបរមា ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ
- សម្របសម្រួលនិងបង្កលក្ខណៈងាយស្រួលដល់ភាគីពាក់ព័ន្ធក្នុងការសិក្សាស្រាវជ្រាវ និងការប្រជុំពិភាក្សាអំពីប្រាក់ឈ្នួលអប្បបរមា ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ

- ផ្តល់អនុសាសន៍អំពីប្រាក់ឈ្នួលអប្បបរមា ប្រាក់ឈ្នួល អត្ថប្រយោជន៍ផ្សេងៗ និងវិសាលភាពនៃការអនុវត្តប្រាក់ឈ្នួលអប្បបរមាជូនរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ផ្សព្វផ្សាយនិងលើកកម្ពស់ការយល់ដឹងនិងការសន្ទនាសង្គមអំពីការកំណត់ប្រាក់ឈ្នួលអប្បបរមា ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈពាក់ព័ន្ធនឹងប្រាក់ឈ្នួល។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ ក.ជ.ប.អ.

**មាត្រា៦ .-**

លើកលែងតែប្រធាន **ក.ជ.ប.អ.** ដែលជារដ្ឋមន្ត្រី សមាជិក **ក.ជ.ប.អ.** មានអាណត្តិ២(ពីរ)ឆ្នាំ ហើយអាចបន្តទៀតបានតាមការស្នើរបស់ក្រសួង ស្ថាប័នសាមី និងអង្គការវិជ្ជាជីវៈពាក់ព័ន្ធ ដូចមានកំណត់នៅក្នុងមាត្រា២ ខាងលើ ស្របតាមនីតិវិធីនៃការជ្រើសរើសសមាជិក **ក.ជ.ប.អ.**។ សមាជិក **ក.ជ.ប.អ.** ត្រូវបន្តការងារនៅក្នុងអាណត្តិរបស់ខ្លួនរហូតដល់មានការប្រកាសតែងតាំងសមាសភាពសម្រាប់អាណត្តិថ្មីមកជំនួស។

**មាត្រា៧ .-**

ករណីដែលសមាជិកពេញសិទ្ធិ ទទួលមរណភាព លាឈប់ ត្រូវបានដកហូត ឬផ្លាស់ប្តូរពីតំណែងដោយប្រការណាមួយ សមាជិកបម្រុងដែលមកពីក្រសួង ស្ថាប័នសាមី ឬអង្គការវិជ្ជាជីវៈពាក់ព័ន្ធនឹងក្លាយជាសមាជិកពេញសិទ្ធិដោយស្វ័យប្រវត្តិរហូតដល់ចប់អាណត្តិ។ ក្នុងរយៈពេលនេះ ប្រធាន **ក.ជ.ប.អ.** អាចស្នើឱ្យក្រសួង ស្ថាប័នសាមីឬអង្គការវិជ្ជាជីវៈពាក់ព័ន្ធ ឧទ្ទេសនាមបេក្ខជនថ្មីជំនួសសមាជិកបម្រុងនោះមុនបញ្ចប់អាណត្តិ បើពិនិត្យឃើញថាចាំបាច់។

**មាត្រា៨ .-**

ក្រៅពីកិច្ចប្រជុំដែលមាននៅក្នុងកាលវិភាគនៃការពិភាក្សាកំណត់ប្រាក់ឈ្នួលអប្បបរមា **ក.ជ.ប.អ.** ត្រូវប្រជុំយ៉ាងតិច២(ពីរ)ដង ក្នុង១(មួយ)ឆ្នាំ។ ប្រធាន **ក.ជ.ប.អ.** អាចកោះប្រជុំបានគ្រប់ពេលទៅតាមការចាំបាច់ ឬទៅតាមសំណើរបស់អនុប្រធានណាមួយ ដោយបញ្ជាក់ពីហេតុផលសមស្របនិងការចាំបាច់។

ប្រធាន **ក.ជ.ប.អ.** ត្រូវរៀបចំរបៀបវារៈនៃកិច្ចប្រជុំដោយពិគ្រោះយោបល់ជាមួយអនុប្រធានទាំង២។ ការប្រជុំត្រូវធ្វើក្នុងអំឡុង៣០(សាមសិប)ថ្ងៃ ក្រោយការរៀបចំរបៀបវារៈ។

ក្នុងករណីដែលសមាជិកពេញសិទ្ធិអវត្តមាន សមាជិកបម្រុងដែលមកពីក្រសួង ស្ថាប័នសាមីឬអង្គការវិជ្ជាជីវៈពាក់ព័ន្ធ ត្រូវចូលរួមប្រជុំជំនួសដោយស្វ័យប្រវត្តិ។

អគ្គលេខាធិការដ្ឋាន **ក.ជ.ប.អ.** ត្រូវរៀបចំលិខិតអញ្ជើញចូលរួមប្រជុំដោយភ្ជាប់ឯកសារពាក់ព័ន្ធនឹងកិច្ចប្រជុំនេះជូនសមាជិកពេញសិទ្ធិនិងសមាជិកបម្រុង ឱ្យបានយ៉ាងតិច១៥(ដប់ប្រាំ)ថ្ងៃ មុនសម័យប្រជុំ។ ក្នុងករណីចាំបាច់និងបន្ទាន់ រយៈពេលនៃការអញ្ជើញនេះ គឺអាស្រ័យទៅលើស្ថានភាពជាក់ស្តែង។

**មាត្រា៩ .-**

កូរ៉ុមសម្រាប់ដំណើរការរាល់កិច្ចប្រជុំរបស់ **គ.ជ.ប.អ.** ត្រូវមានយ៉ាងហោចណាស់ ៥០%+១ (ហាសិបភាគរយបូកមួយ) នៃចំនួនសមាជិកទាំងអស់របស់ **គ.ជ.ប.អ.**។

ការសម្រេចរបស់ **គ.ជ.ប.អ.** ត្រូវធ្វើឡើងដោយមានការឯកភាពជាឯកច្ឆន្ទនៃសមាជិកដែលបានចូលរួមប្រជុំ។ ក្នុងករណីមិនមានការឯកភាពជាឯកច្ឆន្ទលើចំណុចណាមួយចំនួន២(ពីរ)ដងនៅក្នុងកិច្ចប្រជុំចំនួន២(ពីរ)ផ្សេងគ្នា ការសម្រេចត្រូវផ្អែកលើសំឡេងភាគច្រើនដោយការបោះឆ្នោតជាសម្ងាត់នាកិច្ចប្រជុំលើកទី២ នោះ។ ក្នុងករណីទទួលបានសំឡេងស្មើគ្នា សំឡេងប្រធានមានឧត្តមានុភាព។

រាល់កិច្ចប្រជុំរបស់ **គ.ជ.ប.អ.** ត្រូវមានកំណត់ហេតុដែលចុះហត្ថលេខាដោយប្រធាន **គ.ជ.ប.អ.** និងភ្ជាប់មកជាមួយនូវបញ្ជីវត្តមានអ្នកចូលរួមកិច្ចប្រជុំនិងត្រូវផ្ញើជូនសមាជិកពេញសិទ្ធិនិងសមាជិកបម្រុងទាំងអស់ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ក្រោយថ្ងៃប្រជុំ។

**មាត្រា១០ .-**

ក្នុងករណីដែលមានសំណើពីប្រធានឬអនុប្រធានណាមួយ **គ.ជ.ប.អ.** អាចអញ្ជើញបុគ្គល ណាម្នាក់ដែលមានគុណសម្បត្តិគ្រប់គ្រាន់ក្រៅពីសមាជិក ដើម្បីចូលរួមប្រជុំផ្តល់យោបល់លើបញ្ហាដែលត្រូវពិភាក្សា ប៉ុន្តែបុគ្គលនោះមិនមានសិទ្ធិបោះឆ្នោតក្នុងកិច្ចប្រជុំទេ។

**មាត្រា១១ .-**

បទបញ្ញត្តិស្តីពីការបញ្ចេញមតិនិងនីតិវិធីនៃការបោះឆ្នោតរបស់ **គ.ជ.ប.អ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **គ.ជ.ប.អ.**។

**មាត្រា១២ .-**

**គ.ជ.ប.អ.** មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ដែលស្ថិតនៅក្រោមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា១៣ .-**

**គ.ជ.ប.អ.** មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៥
## ប្រភពធនធានរបស់ គ.ជ.ប.អ.

**មាត្រា១៤ .-**

**គ.ជ.ប.អ.** ត្រូវមានថវិកាផ្ទាល់ខ្លួន ជាកញ្ចប់ដាច់ដោយឡែក ដែលជាផ្នែកមួយនៃថវិការបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីដំណើរការការងាររបស់ខ្លួន។ **គ.ជ.ប.អ.** មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់នូវមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

# ជំពូកទី៦
# អវសានប្បញ្ញត្តិ

**មាត្រា១៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៣ កើត ខែ ជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ